**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៩៥ សស/ កសក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើត និងតែងតាំង
## សមាសភាពក្រុមការងារសម្រាប់យេនឌ័រ និងកុមារ
## ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

---

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ ១២៧ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រុមប្រឹក្សាជាតិដើម្បីកុមារ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន
- បានឃើញសេចក្តីសម្រេចលេខ ៤៧៣ កកនអ/ ប្រក.សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ របស់ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបញ្ជ្រាប

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D. Phnom Penh, Cambodia Phone : (023) 726 128 / 726 129. Fax : (855) 23 - 217 320

យេនឌ័រក្នុងកម្មវិធីជួយស្ត្រីកម្ពុជា ដើម្បីបង្កើតសន្តិសុខស្បៀង និងសេដ្ឋកិច្ចគ្រួសារ

- បានឃើញសេចក្តីសម្រេចលេខ ៣០៤ សសរ.កសក.ប ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការបង្កើត និងតែងតាំងសមាសភាពក្រុមការងារសម្រាប់យេនឌ័រ និងកុមារប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សម្រេច

**ប្រការ ១** : ត្រូវបានបង្កើត និងតែងតាំងសមាសភាព ក្រុមការងារសម្រាប់យេនឌ័រ និងកុមារ និងក្រុមលេខាធិការដ្ឋាន ប្រចាំក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានឈ្មោះដូចខាងក្រោម ៖

១. លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន

២. លោកជំទាវ **ម៉ុម ថានី** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៣. លោកជំទាវ **ង៉ូច ហេង** ទីប្រឹក្សាអមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធានអចិន្ត្រៃយ៍

៤. លោកស្រី **គង់ ក្រីស្នា** ព្រឹទ្ធបុរសនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សមាជិក

៥. លោកស្រី **គង់ សុធីរី** ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ សមាជិក

៦. លោកស្រី **ភាំង យឹម** អនុប្រធានរដ្ឋបាលជលផល សមាជិក

៧. លោកស្រី **មាស សុន្ទានី** អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ សមាជិក

៨. លោក **ស្រី ឧុឡារ៉** អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ សមាជិក

៩. កញ្ញា **ខេង្យ សុបញ្ញា** អនុប្រធាននាយកដ្ឋានរដ្ឋបាលព្រៃឈើ សមាជិក

១០.លោកស្រី **អ៊ុក សាវីន** អនុប្រធាននាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សមាជិក

១១.លោកស្រី **ប៉ុល រត្នីសា** ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល សមាជិក

១២.លោកស្រី **ផេង សុផាដា** ប្រធានការិយាល័យ នៃនាយកដ្ឋានផែនការ និងស្ថិតិ សមាជិក

១៣.លោកស្រី **ណារ៉េត ដានីណា** ប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស សមាជិក

១៤.លោកស្រី **ឌុយ សុខខេង** អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកសិកម្ម សមាជិក

១៥.លោកស្រី **សុខ ជារដ្ឋា** អនុប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានកៅស៊ូ សមាជិក

១៦.លោកស្រី **សាន ស៊ីឡេង** អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល សមាជិក

១៧.លោក **យុន សុផាន** អនុប្រធានការិយាល័យ នៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សមាជិក

ដោយមានលេខាធិការដ្ឋានជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម ៖

១. លោកស្រី **ណារ៉េត ដានីណា** ប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស/២

២. លោកស្រី **ម៉ុល រត្និតា** ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល

៣. លោកស្រី **សាខ ស៊ីឡេខ** អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាល

**ប្រការ ២** : ក្រុមការងារយេនឌ័រ និងកុមារ ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ នៅក្នុងវិស័យកសិកម្ម
- អនុវត្តផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ក្នុងវិស័យកសិកម្ម
- តាមដានការអនុវត្ត និងធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស របាយការណ៍៩ខែដើមឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។
- ចូលរួម និងសហការក្នុងក្រុមការងារបច្ចេកទេសយេនឌ័ររបស់ក្រសួងកិច្ចការនារី និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី លើរាល់សកម្មភាពការងារបញ្ជ្រាបយេនឌ័រ
- ពិគ្រោះយោបល់សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហាកុមារ នៅក្នុងក្រសួង
- ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារ នៅក្នុងក្រសួង និងលើកសំណើជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) និងបញ្ហាទាំងឡាយដែលធានាឧត្តមប្រយោជន៍របស់កុមារនៅក្នុងក្រសួង
- ធ្វើការផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព
- រៀបចំផែនការ កម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍របស់កុមារ សម្រាប់ក្រសួង មានជាអាទិ៍ ការគោរព និងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហឹង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាព មកលើកុមារ និងប្រឆាំងនឹងការជួញដូរគ្រឿងញៀន
- បញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីការងាររបស់ក្រសួង
- ធ្វើទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលមានគម្រោងការងារពាក់ព័ន្ធ នឹងកុមារនៅក្នុងក្រសួង ដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចំរើនដែលទាក់ទងនឹងគោលដៅរួម ក្នុងការកែលំអស្ថានភាពកុមារ
- រៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា
- ចាត់ចែងការអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក)
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រគល់ជូន ។

**ប្រការ ៣** : សេចក្តីសម្រេចលេខ ៣០៤ សសរ.កសក.ប ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១១ ស្តីពីការបង្កើត និងតែងតាំងសមាសភាពក្រុមការងារសម្រាប់យេនឌ័រ និងកុមារ ប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី២០ខែឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**<u>កន្លែងទទួល:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងកិច្ចការនារី
-ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន និងយុវនីតិសម្បទា
-ក្រសួងមុខងារសាធារណៈ
-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

**"ដើម្បីជូនជ្រាប"**

-គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-គ្រប់មន្ទីរកសិកម្មខេត្ត និងរាជធានី

**"ដើម្បីជ្រាប"**

-ដូចក្នុងប្រការ ៤

**"ដើម្បីអនុវត្ត"**

-ឯកសារ កាលប្បវត្តិ